# មេរៀនទី៧៣៖ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

## ១ កូរិនថូស ១២៖ ៤- ២៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/y_a0p4-yC-w

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/1-R1XONGbcM

**គោលបំណង៖ ព្រះប្រទានអំណោយទានដល់យើងដើម្បីបំរើព្រះអង្គ។**

**ខគម្ពីរចងចាំ៖ ១ កូរិនថូស ១២៖២៧** *“ រាល់គ្នាជារូបកាយនៃព្រះគ្រីស្ទ ហើយជាអវយវៈរបស់រូប កាយរៀងខ្លួន”។*

**ចំរៀង** ( *យូធូបលីង* )៖

១. គឺជាការល្អដែលសរសើរព្រះ https://youtu.be/Z91SULEHfho
២. ខ្ញុំច្រៀងថ្វាយព្រះនៅក្នុងដួងចិត្តខ្ញុំ https://youtu.be/1th9e8PKFxs
៣. ពេលដែលព្រះវិញ្ញាណបរិសុទ្ធ https://youtu.be/RODHIMCRzw4

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ប្រៀបធៀប»

សម្ភារៈដែលត្រូវការ៖ គ្រូត្រូវត្រៀមក្រដាសឃ្លាមួយចំនួនដែលបរិយាពីកុមារ ដូចជា ( វែង “សក់” ខ្ពស់ “កម្ពស់” ខ្លី “ខោ” ។ល។)

១. យើងចែកកុមារជា ២ក្រុម ហើយឲ្យពួកគេឈរជាជួរ

២. គ្រូនឹងត្រៀមពាក្យក្នុងការប្រៀបធៀប( ធំ តូច វែង ខ្លី ។ល។)

៣. ឧទាហរណ៍៖ ប្រសិនបើគ្រូស្រែកថា “វែង” ក្រុមនីមួយៗត្រូវពិភាក្សាគ្នាថា នរណាដែលមានរបស់វែងច្រើនជាងគេ( ឧទាហរណ៍៖ សក់វែង ខោវែង ដៃវែង។ល។)

៤. ហើយក្រុមនីមួយៗត្រូវរើសកុមារម្នាក់ហើយឲ្យគេទៅឈរខាងមុខ ទាំង២នាក់ បន្ទាប់មកគ្រូក៏បង្ហាញក្រដាសចម្លើយ ( ឧទាហរណ៍ ៖ សក់វែង )

៥. បន្ទាប់មកកុមារទាំងអស់ក៏ចាប់ផ្តើមព្រៀមធៀបកុមារទាំងពីរ ហើយកុមារណាដែលមានសក់វែងជាងគេ ក្រុមនោះនឹងឈ្នះ ហើយទទួលបាន១ពិន្ទុ។

៦. សូមបន្តលេងល្បែងនេះរហូតដល់អស់ពាក្យលេង។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះបានប្រទានពរ និងផ្តល់អំណោយទានឲ្យយើងខុសៗគ្នា។

### ៤. ការណែនាំមេរៀន

**សកម្មភាព៖** ( គ្រូសូមត្រៀមកាដូតូចមួយ ) គ្រូសូមជ្រើសរើសកុមារម្នាក់( អាចជាកុមារដែលនៅខាងមុខ ឬកុមារដែលនៅខាងក្រោយក៏បាន ) ដោយឲ្យកាដូទៅកុមារនោះរួចសួរគេថា “តើកូនសប្បាយចិត្តដែរឬទេ

ដែលទទួលបានកាដូនេះ?”

សូមគិតពីអំណោយដ៏ល្អបំផុតដែលអ្នកធ្លាប់បានទទួលពីនរណាម្នាក់។ តើវាជាសំលៀកបំពាក់ថ្មី? ស្បែកជើងថ្មី? ឬក៏ជាលុយ? ជានិច្ចជាកាលវាជារឿងល្អ ដែលយើងបានទទួលអំណោយពីមនុស្សដែលស្រឡាញ់យើង។ តើអ្នកគិតថាព្រះទ្រង់ស្រឡាញ់យើង ហើយព្រះអង្គប្រទានអំណោយដល់យើងដែរឬទេ? ពិតណាស់! អំណោយដ៏ធំបំផុតដែលព្រះបានប្រទានមកឲ្យយើង នោះគឺជាអំណោយនៃសេចក្តីសង្គ្រោះ។ ព្រះបានប្រទានអំណោយទានពិសេសដល់យើង ដូច្នេះហើយយើងអាចនឹងប្រើអំណោយទានទាំងអស់នោះដើម្បីបំរើព្រះអង្គ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះបានប្រទានអំណោយដល់យើង ប៉ុន្តែអំណោយទាំងនោះមិនដូចគ្នានឹងអំណោយដែលយើងបានឲ្យគ្នាទៅវិញទៅមកទេ។ អំណោយរបស់ព្រះគឺមិនមែនជាប្រដាប់លេងថ្មី ឬហ្គេមថ្មីនោះទេ ប៉ុន្តែអំណោយរបស់ព្រះគឺសំខាន់ជាងរបស់ទាំងនោះ។ ព្រះបានប្រទានអំណោយដល់យើងដើម្បីជួយយើងឲ្យបំរើព្រះ។

ព្រះស្រឡាញ់យើងគ្រប់គ្នា ហើយទ្រង់បានបង្កើតយើងមកខុសៗគ្នា ដូច្នេះហើយយើងអាចជួយគ្នាទៅវិញទៅមកបាន។ ព្រះបានបង្កើតយើងម្នាក់ៗមកជាមនុស្សពិសេស។ ដោយសារយើងមានលក្ខណៈខុសៗគ្នា ព្រះក៏បានប្រទានអំណោយទានឲ្យយើងខុសៗគ្នាដែរ។ ដោយព្រោះអំណោយទានដែលព្រះបានប្រទានឲ្យយើងខុសៗគ្នា គឺមានន័យថា យើងត្រូវយកអំណោយទានរបស់យើងមកប្រើរួមគ្នាជាមួយ នឹងអំណោយទាន របស់គ្រីស្ទបរិស័ទដទៃទៀត។

តើនេះមានន័យថា អំណោយទានរបស់មនុស្សម្នាក់ប្រសើរជាងអំណោយទានរបស់មនុស្សម្នាក់ទៀតមែនឬទេ? ព្រះគម្ពីរបានប្រាប់ថា អំណោយទានមួយចំនួនរបស់ព្រះ គឺជាអំណោយនៃសេចក្តីជំនឿ ការប្រោសជំងឺ អំណាចនៃការអស្ចារ្យ ទំនាយ និងអំណោយទានជាច្រើនទៀត។ តើអ្នកគិតថា អំណោយទាននៃការប្រោសជំងឺ ប្រសើរជាង អំណោយទាននៃសេចក្តីជំនឿដែរឬទេ? ឬក៏អំណោយទាននៃទំនាយប្រសើរជាងអំណោយទាននៃអំណាចនៃការអស្ចារ្យផ្សេងៗដែរឬទេ? មានអំណោយទាននៃព្រះ វិញ្ញាណបរិសុទ្ធជាច្រើនផ្សេងទៀត។ មានមនុស្សមួយចំនួនគឺពូកែ ខាងលើកទឹកចិត្តអ្នកដទៃ ហើយអ្នកដទៃទាំងនោះ ពូកែខាងចែកចាយពីសេចក្តីជំនឿរបស់គាត់ប្រាប់អ្នកដទៃផ្សេងទៀត។ អ្នកខ្លះទៀតមានអំណោយទាន ជាអ្នកដឹកនាំ ហើយមានអ្នកខ្លះទៀតមានអំណោយទានជាអ្នកជួយ។ តើអំណោយទានមួយណាល្អជាង មួយណា?

អត់ទេ! គ្រប់អំណោយទានទាំងអស់សុទ្ធតែសំខាន់។ អំណោយទានរបស់ព្រះបានជួយយើង ដើម្បីឲ្យសំរេចការងារដែលទ្រង់បានប្រទានមកឲ្យយើង។ យើងទាំងអស់គ្នាមានការងារផ្សេងៗគ្នា ហើយមានអំណោយទានផ្សេងៗគ្នា ដើម្បីបំពេញការងារនោះ។ ព្រះគម្ពីរបានប្រើរូបរាងកាយរបស់មនុស្សដើម្បីពន្យល់ថា តើអំណោយទានរបស់អ្នកណាដែលសំខាន់? បើជើងមានអារម្មណ៍ថាខ្លួនមិនសំខាន់ក៏ព្រោះតែជើងគិតថា គេមិនមែនជាដៃ ហើយក៏ឈប់ធ្វើសកម្មភាព តើនឹងមានអ្វីកើតឡើងបើជើងឈប់ធ្វើសកម្មភាព? ឬបើត្រចៀកគិតថា ខ្លួនមិនសំខាន់ដូចជាភ្នែកទេ ហើយត្រចៀកសំរេចចិត្តឈប់ធ្វើការ តើមានអ្វីកើតឡើងចំពោះរូបកាយរបស់យើង? រូបរាងកាយគ្រប់ផ្នែកគឺសុទ្ធតែសំខាន់ ហើយគ្រប់អំណោយទានគឺពិសេសនិងសំខាន់ទាំងអស់។ អ្វីដែលសំខាន់នោះគឺយើងទាំងអស់គ្នាយល់ពីអំណោយទានរបស់យើង និងប្រើ

អំណោយទានទាំងអស់នោះ ដើម្បីបំរើព្រះ និងរាស្ត្ររបស់ព្រះអង្គ។

សូមចំណាយពេល១នាទី ដើម្បីពិចារណាពីអំណោយទានដែលព្រះបានប្រទានមកឲ្យអ្នក។ មានអំណោយទានគ្រប់ប្រភេទទាំងអស់។ អ្វីដែលសំខាន់នោះគឺទូលសុំព្រះបង្ហាញផ្លូវអ្នកឲ្យប្រើអំណោយទានទាំងនោះ។ សូមបិទភ្នែក និងទូលសូមព្រះដើម្បីបង្ហាញផ្លូវអ្នកថា តើអ្វីជាអំណោយទានរបស់អ្នក។ ប្រហែលជាព្រះនឹង ប្រទានពរឲ្យអ្នកមានលទ្ធភាពដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីប្រាប់អ្នកដទៃពីព្រះយេស៊ូវ ឬក៏ ប្រហែលជាអ្នកក្លាយជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំ។

## ៦. សំនួរពិភាក្សា

១. តើព្រះបានផ្តល់អំណោយទានអ្វីខ្លះដល់អ្នក? *(ការសង្គ្រោះ ការទស្សន៍ទាយ ការប្រោសឲ្យជា ។ល។)*

២.តើអំណោយទានមួយណាល្អជាងមួយណា? *(គ្រប់អំណោយទានទាំងអស់សុទ្ធតែល្អ និងសំខាន់ដូចគ្នា។)*

៣.ហេតុអ្វីបានជាព្រះប្រទានអំណោយទានដល់យើងខុសៗគ្នា? *( យើងទាំងអស់គ្នាមានការងារផ្សេងៗគ្នា ហើយមាន អំណោយទានផ្សេងៗគ្នា ដើម្បីបំពេញការងារនោះ។)*

៤. តើអ្នកគិតថា ព្រះបានប្រទានអំណោយទានអ្វីខ្លះដល់អ្នក? *( ទុកឲ្យកុមារជាអ្នកឆ្លើយ )*

## ៧. ល្បែងកំសាន្ត «រត់ប្រណាំងដោយមិនប្រើជើង»



១. បែងចែកកុមារជាក្រុម ដោយក្នុង១ ក្រុមមានកុមារ ពី៤ទៅ៥នាក់

២. ពន្យល់កុមារថា ពួកគេត្រូវរត់ប្រណាំងរហូតដល់ចុងថ្នាក់រៀន។ ពេលដែលកុមារម្នាក់បានទៅដល់ទីមុនគេ កុមារម្នាក់ទៀតនឹងត្រូវប្រណាំងបន្ត។

៣. ក្រុមណាដែលមានសមាជិកទៅដល់ទីបានច្រើនជាងគេគឺជាអ្នកឈ្នះល្បែងនេះ

៤. ទោះជាយ៉ាងណា ក្នុងការប្រណាំងគ្នានេះ ប្អូនៗមិនអាចប្រើជើងបានទេ។ ( ឲ្យកុមារមានគំនិតឆ្នៃប្រឌិត )

៥. ត្រៀមខ្លួនហើយនៅ ចេញដំណើរ!



៦. បន្ទាប់ពីលេងល្បែងនេះចប់៖ តើប្អូនមានការពិបាកយ៉ាងណា ដែលយើងរត់ប្រណាំងដោយមិនប្រើជើងបែបនេះ? សូមចាំថាគ្រប់ ផ្នែកទាំងអស់នៃរាងកាយរបស់អ្នកគឺសំខាន់ដូចគ្នាមិនថា វាតូចឬមើលទៅមិនសំខាន់ក៏ដោយ នៅក្នុងផ្លូវតែមួយ គ្រប់ផ្នែក នៃអំណោយទានដែលព្រះបានប្រទានមកឲ្យ យើងគឺសុទ្ធតែសំខាន់ និងពិសេស! សូមប្រើអំណោយទាន របស់អ្នកដោយប្រាជ្ញាដើម្បីបំរើព្រះ និងរាស្ត្ររបស់ទ្រង់។

## ៨. ខគម្ពីរចងចាំ

**១ កូរិនថូស ១២៖២៧** *" រាល់គ្នាជារូបកាយនៃព្រះគ្រីស្ទ ហើយជាអវយវៈរបស់រូបកាយរៀងខ្លួន"*។

## ៩. ហត្ថកម្ម «យើងគឺតែមួយ!»

សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពក្រដាសរូបតុក្កតា (សូមមើលនៅទំព័រខាងក្រោម) ខ្មៅដៃពណ៌ កន្ត្រៃ ស្កុតបិត ឬកាវបិត។

១. ឲ្យក្រដាសដែលបានបោះពុម្ពរួចទៅកុមារម្នាក់១សន្លឹក



២. ឲ្យកុមារសរសេរឈ្មោះរបស់ពួកគេ និងតុបតែង លើក្រដាសនោះ។

៣.ពេលដែលកុមារទាំងអស់ធ្វើរួចហើយ សូមយកក្រដាសទាំងអស់របស់កុមារគ្រប់គ្នា មកបិតជាប់គ្នាហើយបិទក្រដាសនោះនៅលើជញ្ជាំងក្នុងថ្នាក់រៀន។

៤. ពន្យល់កុមារថា ទោះជាក្រដាសតុក្កតាមានឈ្មោះខុសគ្នា ហើយមានការតុបតែងខុសគ្នាក៏ដោយ តែវាមានទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងរូបកាយតែមួយ។ នៅក្នុងអត្ថន័យតែមួយ យើងមានលក្ខណៈខុសៗគ្នា តែយើងជារូបកាយតែមួយរបស់ព្រះគ្រីស្ទ។ សូមឲ្យយើងប្រើអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបំរើព្រះ និងបំរើរាស្ត្រទ្រង់។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
វាពិតជាអស្ចារ្យណាស់ដែលដឹងថាព្រះបានចែករំលែកផ្នែកមួយនៃសមត្ថភាពរបស់ព្រះយេស៊ូវ នោះគឺជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធឲ្យមកយើងគ្រប់ៗគ្នា។ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ របស់អ្នកគឺជាព្រះពរដែលព្រះបានប្រទានឱកាសឲ្យបានដូចជាព្រះយេស៊ូវ។ តើអ្នកបានយកពេលវេលាមកឆ្លុះបញ្ចាំងថាតើអ្វីជាអំណោយនៃព្រះវិញ្ញាណបរិសុទ្ធរបស់អ្នក? តើអ្នកបានយកពេលមកអភិវឌ្ឍន៍អំណោយទានរបស់អ្នកដែរឬទេ? សូមចាំថាអំណោយទានរបស់អ្នកត្រូវបានប្រទានឲ្យអ្នកដើម្បីឲ្យអ្នកសង់រូបកាយរបស់ព្រះយេស៊ូវ។ វាជាការទទួលខុសត្រូវរបស់អ្នក។

# យើងគឺតែមួយ!




